# គោលការណ៍ និងលក្ខខណ្ឌ

## របស់កម្មវិធីប្រូម៉ូសិនជាមួយប័ណ្ណឥណទានវីសា

I. **ផលិតផល៖** ប័ណ្ណឥណទានវីសារបស់ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី។

II. **រយៈពេលនៃការអនុវត្ត៖** ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤។

III. **ព័ត៌មានលម្អិតអំពីកម្មវិធីប្រូម៉ូសិន៖**

<table>
<tr><th>កម្មវត្ថុ</th><th>ការផ្តល់ជូន</th></tr>
<tr><td>អតិថិជនថ្មី</td><td>
<ul>
<li>មិនគិតកម្រៃសេវាសម្រាប់ឆ្នាំដំបូងសម្រាប់ប័ណ្ណឥណទានវីសាមិនមានទ្រព្យធានា (Unsecured credit card) ឬមិនគិតកម្រៃសេវាសម្រាប់ប័ណ្ណឥណទានវីសាមានទ្រព្យធានា (Secured credit card)។</li>
<li>ទទួលបានសំបុត្រ E-ticket ចំនួន១កូដសម្រាប់មើលភាពយន្តនៅរោងភាពយន្ត Legend ជាមួយនឹងមួយប្រតិបត្តិការដំបូងយ៉ាងតិច ៣០ដុល្លារ។</li>
</ul>
</td></tr>
<tr><td>គ្រប់ម្ចាស់ប័ណ្ណ</td><td>
a. រីករាយជាមួយទឹកប្រាក់ត្រលប់មកវិញរៀងរាល់សប្តាហ៍នៅពេលចំណាយជាមួយប័ណ្ណឥណទានវីសា៖
<table>
<tr><th>ទឹកប្រាក់ត្រលប់មកវិញ</th><th>អនុវត្ត</th></tr>
<tr><td>៣ដុល្លារ</td><td>សម្រាប់រាល់ចំណាយទូទាត់នៅតាមបណ្តារស្ថានីយ៍ប្រេងឥន្ធនៈយ៉ាងតិចចំនួន ៣០ដុល្លារ។</td></tr>
<tr><td>១០ដុល្លារ</td><td>សម្រាប់រាល់ចំណាយទូទាត់អនឡាញ៍ទិញដំណើរកំសាន្ត ទិញសំបុត្រយន្តហោះ និងកក់សណ្ឋាគារយ៉ាងតិចចំនួន ១០០ដុល្លារ។</td></tr>
</table>
b. មិត្តកាន់តែច្រើន – អំណោយកាន់តែច្រើន (កម្មវិធីណែនាំ)៖
<table>
<tr><th>កម្មវត្ថុ</th><th>ការផ្តល់ជូន</th></tr>
<tr><td>សម្រាប់អ្នកណែនាំ</td><td rowspan="2">ទទួលបានសំបុត្រ E-ticket ចំនួន១កូដសម្រាប់មើលភាពយន្តនៅរោងភាពយន្ត Legend ចំពោះប័ណ្ណបានដំណើរការ (Activate)អោយជោគជ័យ។</td></tr>
<tr><td>សម្រាប់ម្ចាស់ប័ណ្ណថ្មី</td></tr>
</table>
</td></tr>
</table>

IV. **គោលការណ៍ និងលក្ខខណ្ឌ៖**

1- **សម្រាប់អតិថិជនថ្មី៖**

- **អតិថិជនថ្មី៖** គឺជាអតិថិជនមិនធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី ពីមុនមក ឬសម្រាប់អតិថិជនចាស់ដែលធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី អាចទទួលបានប្រូម៉ូសិនដូច "អតិថិជនថ្មី" ប្រសិនបើបិទប័ណ្ណមុន ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២៣។
- អតិថិជនថ្មី ដែលស្នើសុំប័ណ្ណឥណទានវីសាមិនមានទ្រព្យធានា (Unecured credit card) នឹងមិនគិតកម្រៃសេវាឆ្នាំដំបូង និងអតិថិជនថ្មីដែលស្នើសុំប័ណ្ណឥណទានវីសាដែលមានទ្រព្យធានា (Secured Credit Card) នឹងមិនគិតកម្រៃសេវាធ្វើឯកសារចំពោះប័ណ្ណបានដំណើរការ (Activate) ជោគជ័យ។

- ធនាគារសាខមប៉េង ខេមបូឌា ភីអិលស៊ី នឹងប្តូរទៅជាកូដគិតកម្រៃសេវាធម្មតាប្រសិនបើម្ចាស់ប័ណ្ណមិនបានដំណើរការ (Activate) ក្នុងអំឡុងពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃដែលចេញប័ណ្ណ។
- ម្ចាស់ប័ណ្ណដែលចំណាយយ៉ាងតិច ៣០ដុល្លារ លើប្រតិបត្តិការទិញ/ទូទាត់តែមួយតាមរយៈប័ណ្ណឥណទានវីសាក្នុងអំឡុងពេលកម្មវិធីប្រូម៉ូសិននឹងទទួលបានសំបុត្រ E-ticket ចំនួន១កូដ នៅរោងភាពយន្ត Legend។
- លេខកូដសំបុត្រ E-ticket នៅរោងភាពយន្ត Legend នឹងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទដែលបានចុះឈ្មោះនៅថ្ងៃធ្វើការបន្ទាប់ចាប់ពីថ្ងៃដែលមានលក្ខខណ្ឌគ្រប់គ្រាន់។
- ប្រត្តិបត្តិការដែលគ្រប់លក្ខខណ្ឌមិនរួមបញ្ចូល MCC-6011,6012 (លេខកូដប្រភេទពាណិជ្ជករៈដកសាច់ប្រាក់)។
- ការផ្តល់ជូនមានចំនួនកំណត់ មកមុនបានមុនរហូតដល់អស់ពីស្តុក។

## 2- សម្រាប់គ្រប់ម្ចាស់ប័ណ្ណទទួលបានការផ្តល់ជូនទឹកប្រាក់ត្រឡប់មកវិញ៖

### 2.1. ទឹកប្រាក់ត្រឡប់មកវិញ ៣ដុល្លារ សម្រាប់រាល់ចំណាយទូទាត់នៅតាមបណ្តារស្ថានីយ៍ប្រេងឥន្ធនៈ៖

- ម្ចាស់ប័ណ្ណអាចទទួលបានទឹកប្រាក់ត្រឡប់មកវិញ៣ដុល្លារ សម្រាប់រាល់ចំណាយនៅតាមបណ្តារស្ថានីយ៍ប្រេងឥន្ធនៈយ៉ាងតិចចំនួន៣០ដុល្លារ។
- ម្ចាស់ប័ណ្ណម្នាក់ៗអាចទទួលបានប្រាក់សងត្រឡប់មកវិញចំនួន១ដងក្នុងមួយសប្តាហ៍ ហើយអតិបរមាចំនួន៣ដងអំឡុងពេលនៃកម្មវិធីប្រូម៉ូសិន។
- **"ការចំណាយដែលគ្រប់លក្ខខណ្ឌ"** គឺជាការធ្វើឡើងដោយប័ណ្ណចម្បង និងប័ណ្ណរងហើយបំពេញលក្ខខណ្ឌនៃ MCC (លេខកូដប្រភេទពាណិជ្ជករៈ ស្ថានីយ៍ប្រេងឥន្ធនៈ) តាមរយៈម៉ាស៊ីន POS។

### 2.2. ទឹកប្រាក់ត្រឡប់មកវិញ ៣ដុល្លារ សម្រាប់រាល់ចំណាយទូទាត់ទូទាត់អនឡាញ៉៖

- ម្ចាស់ប័ណ្ណអាចទទួលបានទឹកប្រាក់ត្រឡប់មកវិញ ១០ដុល្លារ សម្រាប់រាល់ចំណាយទូទាត់អនឡាញ៉ទិញដំណើរកំសាន្ត ទិញសំបុត្រយន្តហោះ និងកក់សណ្ឋាគារយ៉ាងតិចចំនួន ១០០ដុល្លារ។
- ម្ចាស់ប័ណ្ណម្នាក់ៗអាចទទួលបានប្រាក់សងត្រឡប់មកវិញចំនួន១ដង អំឡុងពេលនៃកម្មវិធីប្រូម៉ូសិន។
- **"ប្រត្តិបត្តិការអនឡាញ៉"** គឺជាវិធីសាស្រ្តទូទាត់តាមរយៈអ៊ីនធឺណិតដែលធ្វើឡើងនៅលើ E-commerce trading platform គេហទំព័រដែលទទួលយកការទូទាត់ជាមួយប័ណ្ណវីសា។

- ចំនួនទឹកប្រាក់ត្រឡប់មកវិញនៃប្រតិបត្តិការគ្រប់លក្ខខណ្ឌនឹងបញ្ចូលនៅថ្ងៃបន្ទាប់នៃថ្ងៃធ្វើការ។
- ប្រតិបត្តិការដែលមិនបានបង្ហោះ ឬលុបចោល ឬបង្វិលសងវិញទាំងស្រុង ឬមួយផ្នែក និងមិនគ្រប់លក្ខខណ្ឌហើយធនាគារសាខមប៉េង ខេមបូឌា ភីអិលស៊ី នឹងយកមកវិញដោយកាត់ចេញលើចំនួនទឹកប្រាក់សងត្រឡប់មកវិញពីប័ណ្ណឥណទានរបស់លោកអ្នក។
- ការផ្តល់ជូនមានចំនួនកំណត់ មកមុនបានមុនរហូតដល់អស់ពីស្តុក។

### 2.3. កម្មវិធីណែនាំ៖

- សម្រាប់អ្នកណែនាំ និងសម្រាប់ម្ចាស់ប័ណ្ណថ្មីអ្នកទាំងពីរនាក់អាចទទួលបានលេខកូដសំបុត្រ E-ticket នៅរោងភាពយន្ត Legend ចំពោះប័ណ្ណបានដំណើរការ (Activate) ជោគជ័យ។
- សម្រាប់អ្នកណែនាំ និងសម្រាប់ម្ចាស់ប័ណ្ណថ្មីអាចទទួលបានការផ្តល់ជូនជាច្រើនក្នុងពេលតែមួយប្រសិនបើពួកគេបំពេញគ្រប់លក្ខខណ្ឌ។

Sacombank

- លេខកូដសំបុត្រ E-ticket សម្រាប់មើលភាពយន្តនៅរោងភាពយន្ត Legend នឹងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទដែលបានចុះឈ្មោះនៅថ្ងៃធ្វើការបន្ទាប់ចាប់ពីថ្ងៃដែលមានលក្ខខណ្ឌគ្រប់គ្រាន់។

## V. លក្ខខណ្ឌផ្សេងទៀត៖

- ប្រតិបត្តិការដែលជោគជ័យ (ម្ចាស់ប័ណ្ណនឹងទទួលបានសារជូនដំណឹងពីធនាគារ) ប៉ុន្តែបើក្នុងរយៈពេល៣០ថ្ងៃប្រតិបត្តិការទាំងនោះមិនបានកត់ត្រាចូលទៅក្នុងរបាយការណ៍នឹងត្រូវចាត់ទុកជាប្រតិបត្តិការមិនគ្រប់លក្ខខណ្ឌ។
- វិវាទ ការលុបចោល និង/ឬ ប្រតិបត្តិការបរាជ័យក្នុងអំឡុងពេលប្រូម៉ូសិននឹងត្រូវកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌ។
- រាល់ប្រតិបត្តិការដែលមានការសង្ស័យ ឬមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដោយផ្អែកលើពេលវេលាទីតាំងរបស់ប្រតិបត្តិការ ឬកត្តាផ្សេងទៀតនឹងត្រូវកាត់ចេញពីប្រតិបត្តិការដែលមានលក្ខខណ្ឌមុន។ ធនាគារមានសិទ្ធិក្នុងការស្នើសុំអតិថិជនក្នុងការផ្តល់វិក័យប័ត្រហិរញ្ញវត្ថុដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការ។ ក្នុងករណីដែលអតិថិជនខកខានមិនបានបង្ហាញពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការនោះទេ នោះធនាគារនឹងធ្វើការកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌនោះ។
- ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី មានសិទ្ធិបដិសេធនូវរាល់ពាក្យស្នើសុំដែលមិនគ្រប់លក្ខខណ្ឌមិនច្បាស់លាស់មិនគ្រប់គ្រាន់ និង/ឬ ឯកសារយោងមិនសមស្រប។

## VI. ព័ត៌មានបន្ថែម៖

- សម្រាប់ព័ត៌មានបន្ថែមអតិថិជនអាចអញ្ជើញមកកាន់សាខាណាមួយរបស់ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី ឬទំនាក់ទំនងមកកាន់ភ្នាក់ងារបម្រើអតិថិជន៖ ០២៣ ២២៣ ៤២៣ និង ០៩៧ ៨ ២២៣ ៤២៣។
- ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី ទទួលខុសត្រូវ ក្នុងការជូនដំណឹងទៅលើគោលការណ៍ និងលក្ខខណ្ឌនៃកម្មវិធីនេះ និងព័ត៌មានរបស់អតិថិជនដែលគ្រប់លក្ខខណ្ឌ (រួមមាន ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែននិងលេខបួនខ្ទង់ចុងក្រោយរបស់ប័ណ្ណចម្បងឥណទានវីសា) តាមរយៈគេហទំព័ររបស់ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី៖ sacombank.com.kh ដោយមិនជូនដំណឹងជាមុន។

## VII. លក្ខខណ្ឌទូទៅ៖

- ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី មិនទទួលខុសត្រូវ ចំពោះការមិនបានជូនដំណឹង ដោយសារបញ្ហាប្រព័ន្ធ Email អាសយដ្ឋាន ឬលេខទូរស័ព្ទដែលផ្តល់ដោយម្ចាស់ប័ណ្ណ ឬលិខិតជូនដំណឹងត្រូវបាត់ លួច ឬខូច។
- ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌទាំងនេះនៅពេលណាមួយដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុន។
- ក្នុងករណីមានវិវាទណាមួយកើតឡើងទាក់ទងនឹងកម្មវិធីប្រូម៉ូសិននេះ ធនាគារសាខមប៉ែង ខេមបូឌា ភីអិលស៊ី និងដោះស្រាយវិវាទនេះយ៉ាងសមស្របបំផុតទៅកាន់អតិថិជនប្រសិនបើបរាជ័យក្នុងការដោះស្រាយវិវាទនោះនឹងត្រូវបានដោះស្រាយទៅតាមផ្លូវច្បាប់ដែលបានកំណត់។
- តាមរយៈការចូលរួមក្នុងកម្មវិធីនេះគ្រប់ម្ចាស់ប័ណ្ណទាំងអស់ត្រូវចាត់ទុកថាទទួល និងយល់ព្រមនូវគោលការណ៍នឹងលក្ខខណ្ឌរបស់កម្មវិធី។